**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

# <u>សេចក្តីប្រកាសព័ត៌មាន</u>

## ស្តីពីលទ្ធផលនៃកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសមេគង្គ-ជប៉ុនលើកទី១៤
## ថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២១ តាមប្រព័ន្ធវីដេអូ

-------------

នៅថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២១ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ប្រាក់ សុខុន រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសមេគង្គ-ជប៉ុនលើកទី១៤ តាមប្រព័ន្ធវីដេអូ ដែលកិច្ចប្រជុំនេះ ដឹកនាំដោយ ឯកឧត្តម ម៉ូតេហ្គី តូស៊ីមីស៊ី រដ្ឋមន្ត្រីការបរទេសជប៉ុន និងមានការអញ្ជើញចូលរួមពីរដ្ឋមន្ត្រីការបរទេសនៃបណ្តាប្រទេសមេគង្គផ្សេងទៀត រួមមាន ឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម។

រដ្ឋមន្ត្រីការបរទេសមេគង្គ-ជប៉ុន បានពិនិត្យឡើងវិញនូវវឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការមេគង្គ-ជប៉ុន ក្នុងវិស័យជាអាទិភាព និងបានកំណត់ទិសដៅអនាគតនៃកិច្ចសហប្រតិបត្តិការនេះ ដើម្បីជំរុញការអភិវឌ្ឍប្រកបដោយចីរភាព លើកកម្ពស់ការតភ្ជាប់ផ្នែកសង្គម សេដ្ឋកិច្ច និងវប្បធម៌រវាងបណ្តាប្រទេសមេគង្គនិងជប៉ុន និងដើម្បីធានាឱ្យបាននូវអនុតំបន់មេគង្គដែលកាន់តែរស់រវើក ដោយគិតគូរពិចារណាទៅលើជំងឺរាតត្បាតកូវីដ-១៩ និងការប្រឈមនានាដែលកំពុងកើតមាន។ ទន្ទឹមនេះដែរ រដ្ឋមន្ត្រីទាំងអស់ បានលើកឡើងអំពីតួនាទីដ៏សំខាន់របស់ក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការមេគង្គ-ជប៉ុន នៅក្នុងការថែរក្សាបាននូវសន្តិភាព និងស្ថិរភាព នៅក្នុងអនុតំបន់មេគង្គ និងឥណ្ឌូ-ប៉ាស៊ីហ្វិក។

ឆ្លៀតក្នុងឱកាសនេះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់ថា ការតភ្ជាប់ផ្នែកទន់និងផ្នែករឹង ដំណើរការដោយរលូននៃខ្សែច្រវាក់ផ្គត់ផ្គង់សកល ការគាំទ្រដល់សហគ្រាសធុនមីក្រូ តូច និងមធ្យម (MSMEs) ការជំរុញឱ្យមានការធ្វើដំណើរឡើងវិញតាមរយៈការទទួលស្គាល់ប័ណ្ណចាក់វ៉ាក់សាំងកូវីដ-១៩ និងឌីជីថលូបនីយកម្មលើវិស័យពាក់ព័ន្ធនានា គួរតែត្រូវបានដាក់ចេញឱ្យអនុវត្ត ដោយការយកចិត្តទុកដាក់ខ្ពស់បំផុត ដើម្បីធានាឱ្យបាននូវភាពធន់ និងចីរភាពនៅក្នុងអនុតំបន់ ក្នុងអំឡុងពេល និងក្រោយវិបត្តិនៃជំងឺរាតត្បាតកូវីដ-១៩ ។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានស្នើឱ្យមិត្តជប៉ុន និងបណ្តាប្រទេសមេគង្គ គិតគូរពិចារណាលើគំនិតផ្តួចផ្តើមរបស់កម្ពុជា ក្នុងការបង្កើតក្រុមការងាររួមសិក្សាលើ «សេណារីយ៉ូស្តារសេដ្ឋកិច្ចមេគង្គ-ជប៉ុន» ដើម្បីរិះរកនូវលទ្ធភាពស្តារសេដ្ឋកិច្ចនានាក្នុងការធ្វើឱ្យឧស្សាហកម្មទេសចរណ៍ សហគ្រាសធុនមីក្រូ តូច និងមធ្យម (MSMEs) និងការវិនិយោគដែលជាប់គាំង

អាសយដ្ឋាន: លេខ ៣ វិថី **សម្តេច ហ៊ុន សែន**
សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 541
អ៊ីម៉ែល : mfaic@mfaic.gov.kh

បំផុតក្នុងអនុតំបន់នេះ មានដំណើរការឡើងវិញ។ គំនិតផ្តួចផ្តើមនេះត្រូវបានគាំទ្រដោយប្រធានអង្គប្រជុំ និងអ្នកចូលរួមក្នុងកិច្ចប្រជុំទាំងអស់។

កិច្ចប្រជុំនេះត្រូវបានបញ្ចប់ប្រកបដោយផ្លែផ្កាគួរជាទីមោទក តាមរយៈការយល់ឃើញរួមគ្នាលើបញ្ហាតំបន់ និងអន្តរជាតិនានា ជាពិសេសកិច្ចខិតខំប្រឹងប្រែងរួមគ្នាក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺរាតត្បាតកូវីដ-១៩ និងការប្តេជ្ញាចិត្តក្នុងការស្តារសេដ្ឋកិច្ចក្នុងតំបន់ឡើងវិញក្រោយវិបត្តិនៃជំងឺរាតត្បាតកូវីដ-១៩ ត្រូវបានបញ្ចប់៕

ថ្ងៃសុក្រ ១៣រោច ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២១